# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## កិច្ចព្រមព្រៀង
## រវាង តំណាងបុគ្គលិក សណ្ឋាគារ សុខាអង្គរ
## និង និយោជកនៃ សណ្ឋាគារ សុខាអង្គរ

អនុស្សរណៈនៃការយោគយល់នេះត្រូវបានធ្វើឡើងនៅថ្ងៃទី១២ ខែមករា ឆ្នាំ២០២៤ រវាង បុគ្គលិកនៃសណ្ឋាគារ សុខាអង្គរ (ពីនេះតទៅហៅថា "តំណាងបុគ្គលិក") និងតំណាងសណ្ឋាគារ សុខា អង្គរ (ពីនេះតទៅហៅថា "និយោជក")។

ដោយសារតែមកទល់ពេលបច្ចុប្បន្ននេះស្ថានភាពសេដ្ឋកិច្ច និងពាណិជកម្មគ្រប់វិស័យនៅលើពិភពលោក រួមទាំងប្រទេសកម្ពុជាយើងផងដែរ នៅតែទទួលរងនូវបញ្ហាប្រឈម ជាពិសេសវិស័យទេសចរណ៍ និងបដិសណ្ឋារកិច្ច។ អាស្រ័យហេតុនេះ ដើម្បីសម្រាលនូវបញ្ហាប្រឈមដ៏ធ្ងន់ធ្ងរនៅចំពោះមុខនេះ តំណាងនិយោជក និងនិយោជិតបានចរចារ និងព្រមព្រាងគ្នាដាក់ឲ្យបុគ្គលិកចំនួន **៧៣នាក់ ស្រី ៣១នាក់** បន្តឈប់សម្រាកពីការងារដោយឥតប្រាក់ឈ្នួល រយៈពេលហុកសិបថ្ងៃ(៦០)ថ្ងៃទៀត **គិតចាប់ពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២៤ ដល់ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៤។**

ភាគីទាំងពីរបានព្រមព្រៀងគ្នា លើលក្ខខណ្ឌដូចខាងក្រោម៖

- និយោជិតដែលត្រូវបានដាក់ឲ្យឈប់សម្រាកពីការងាររយៈពេលហុកសិបថ្ងៃ(៦០)ថ្ងៃ នឹងមិនទទួលបានប្រាក់ឈ្នួល និងប្រាក់ធានានុគ្រោះទេ នៅក្នុងអំឡុងពេលនៃការឈប់សម្រាកនេះ។
- និយោជក នឹងរក្សាទុកក្នុងកម្មករនិយោជិតចំនួនអប្បបរមា ទៅតាមតម្រូវការជាក់ស្តែងនៃផ្នែកនិមួយៗ។

សូមបញ្ជាក់ថា ចំណុចដូចដែលបានរៀបរាប់ខាងលើនេះ គឺសម្រាប់ការអនុវត្តរយៈពេលហុកសិបថ្ងៃ(៦០)ថ្ងៃ គិតចាប់ពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២៤ ដល់ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៤។ ក្រុមហ៊ុននឹងធ្វើការជូនដំណឹងជាថ្មីបើសិនស្ថានការណ៍មានការប្រែប្រួល ហើយគូភាគីនឹងពិនិត្យមើលអនុស្សរណៈនៃការយោគយល់នេះ ឡើងវិញ។

សណ្ឋាគារសុខាអង្គរ
SOKHA ANGKOR HOTEL
BRANCH OF SOKHA HOTEL CO.,LTD.

Scanned with CamScanner

**ហត្ថលេខាភាគីតំណាងនិយោជក**

SOKHA ANGKOR HOTEL
BRANCH OF SOKHA HOTEL CO LTD.

ប៊ុន ម៉េង

**ហត្ថលេខាភាគីតំណាងនិយោជិត**

Leng Lim

Chinda

Try Sotheda

Scanned with CamScanner